**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ធនាគារ ស្ថាបនា
SATHAPANA BANK

លេខអត្តសញ្ញាណកម្ម: L00១-១000៤៧១៧៣
លេខ: FIN 001

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ជាទីគោរពដ៏ខ្ពង់ខ្ពស់!

តាងនាមថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់របស់ ធនាគារ ស្ថាបនា ភីអិលស៊ី យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតដែលអគ្គនាយកដ្ឋានពន្ធដារ បានសំរេចផ្តល់វិញ្ញាបនបត្រ អនុលោមភាពសារពើពន្ធប្រភេទមាស ដល់ធនាគារយើងខ្ញុំ។ ធនាគារ ស្ថាបនា ភីអិលស៊ី ពិតជាមានកិត្តិយសយ៉ាងខ្លាំងដែលបានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាសនេះដែលបញ្ជាក់អោយឃើញពីការគោរពប្រតិបត្តិច្បាប់ និងបទប្បញ្ញត្តិរបស់អគ្គនាយកដ្ឋានពន្ធដារក៏ដូចជារបស់រាជរដ្ឋាភិបាលកម្ពុជាពីសំណាក់ធនាគារយើងខ្ញុំ។ ធនាគារ ស្ថាបនា ភីអិលស៊ី និងបន្តព្យាយាមគោរពយ៉ាងម៉ឹងម៉ាត់ក្នុងការអនុវត្ត ច្បាប់កាតព្វកិច្ចក្នុងការបង់ពន្ធ និងកាតព្វកិច្ចជាភ្នាក់ងារពន្ធដារក្នុងការប្រមូលពន្ធអាករផ្សេងៗជូនអគ្គនាយកដ្ឋានពន្ធដារ។ យើងខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ធនាគារ ស្ថាបនា ភីអិលស៊ី នឹងបន្តទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ប្រភេទមាសនៅពេលខាងមុខជាបន្តទៀត។

ជាថ្មីម្តងទៀត ធនាគារ ស្ថាបនា ភីអិលស៊ី សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត និងសូមគោរពជូនពរ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារទាំងអស់** ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខនេះ សូមមានសុខភាពល្អបរិបូរណ៌ ពលានុភាពខ្លាំងក្លា ប្រាជ្ញាវាងវៃ ជោគជ័យគ្រប់ភារកិច្ច និងសមប្រកបតែពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាទទួលនូវកាគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**ប្រធាននាយកប្រតិបត្តិ**

SATHAPANA BANK PLC.

**ណូរិហិកុ កាតុ**

023 999 010 info@sathapana.com.kh www.sathapana.com.kh
No. 83, Preah Norodom Boulevard, Sangkat Phsar Thmey 3, Khan Daun Penh, Phnom Penh, Cambodia